-40-ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ ៖ ១០៧

ចុះថ្ងៃទី០២ខែមិនាឆ្នាំ២០០០

សាលដីកា

លេខ ៖ ១២៥

ចុះថ្ងៃទី២៣ខែសីហាឆ្នាំ២០០១

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៣សីហា២០០១ដោយ

មានសមាសភាពដូចតទៅ ៖ –

១– ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២– លោក ស៊ិន ឌឹម ជាចៅក្រមរបាយការណ៍

៣– លោក ប្រាក់ គឹមសាន ជាចៅក្រម

៤– លោក យស់ សួខវឺន ជាចៅក្រម

៥– លោក គង់ ភីរុណ ជាចៅក្រម

ក្រឡាបញ្ជី

លោក ល៉ុង ម៉ៅ

តំណាងមហាអយ្យការ

លោក ប៉ែន សារឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ៥០៨ ចុះថ្ងៃទី១៤.០១.៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៤០៣ ចុះថ្ងៃទី២៩ខែមិថុនាឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ រវាង ៖ –

ម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ពោន សារឿន ភេទប្រុស អាយុ ៥៦ ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើពេទ្យស្រុក ទីលំនៅសព្វថ្ងៃភូមិប្របែស្រមុខ ឃុំកញ្ជៀច ស្រុកកញ្ជៀច ខេត្តព្រៃវែង ។ ឪពុកឈ្មោះ ពោន ម៉ន ម្តាយឈ្មោះ ញ៉ឹម សន ប្រពន្ធឈ្មោះ នោម សារី មានកូន០៦នាក់ ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ ផន វ៉ាន់ធូ ភេទប្រុស អាយុ ២៦ ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិប្របែស្រមុខ ឃុំ – ស្រុក កញ្ជៀច ខេត្តព្រៃវែង ។ ឪពុកឈ្មោះ ស៊ូ អេងឃី ម្តាយឈ្មោះ នៀវ អាន ប្រពន្ធឈ្មោះ វៀត សុផល ។

កម្មវត្ថុ ៖ ប្តឹងទាមទារសំណង ២០០០ដុល្លា

បានឃើញបណ្តឹងសាទុក្ខលេខ ៤៦៨ ចុះថ្ងៃទី ១៨ខែ តុលា ឆ្នាំ ១៩៩៩ របស់ឈ្មោះជុំ សោភា មេធាវីរបស់លោក ពោន សារឿន មិនសុខចិត្តនិងសាលដីការដ្ឋប្បវេណីលេខ ៥០៨ ចុះថ្ងៃទី១៤ខែ តុលា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំនុច សេចក្តីសំរេចសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១០៧ ចុះថ្ងៃទី ០២ មិនា ២០០០ របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៣.១១.៩៨ របស់ ផន វ៉ាន់ធូ ប្តឹងទាមទារសំណង២០០០ដុល្លាអាមេរិកពីឈ្មោះ ពោន សារឿន ដោយហេតុថា នាលចុងខែកក្កដា១៩៩៨ កូនរបស់ខ្លួនមានជំងឺក្តៅខ្លួនក៏បានយកកូនទៅព្យាបាលនៅផ្ទះពោន សារឿន ពេលនេះថាមានជំងឺស្លូត ហើយក៏ចាក់ថ្នាំកាតរ័ចំនួន៣ម្ជុល

ចាក់លើផ្ទះទាំងសងខាង និង ចាក់ពីក្រោយត្រង់ស្លាបប្រចៀវខាងឆ្វេង១មួយ ឯពីរមួលទៀត ថ្នាំធម្មតា២មួលចាក់ភ្លៅ គិតជាប្រាក់២៦.០០០រៀល ។ មួយខែក្រោយមកស្នាមមុខមួលបើកខ្លែង ផ្នែកខាងលើផតទាំងអស់ ខ្លួនសួរពេទ្យថាមិនអីទេ តែដល់ពេលខ្លួនដកកូនទៅពិនិត្យពេទ្យខេត្ត ខេត្ត បានបញ្ជាក់ថា ស្វិតជាលិកាខ្លាញ់ គឺផតផ្ទះទាំងសងខាង និង ស្លាបប្រចៀវខាងឆ្វេង មិនអាច ជាឡើងវិញ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៩ ចុះថ្ងៃទី១០ខែមិនា ឆ្នាំ ១៩៩៩ របស់តុលាការខេត្ត ព្រៃវែង មានសេចក្តីដូចតទៅ :-

១- ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ ផន វ៉ាន់ធូ ចុះថ្ងៃទី ១៣.១១ ឆ្នាំ ១៩៩៨ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- បង្គាប់អោយចុងចម្លើយឈ្មោះ ពោន សារឿន បង់ប្រាក់សងទៅដល់ដើមបណ្តឹងចំនួន ១៥០០ដុល្លាអាមេរិក ថ្លៃដំដីចិត្ត និង ថ្លៃចាក់ថ្នាំបណ្តាលអោយខូចទ្រង់កាយ " ស្វិតជាលិកាខ្លាញ់ ផ្ទះទាំងសងខាងនិងស្វិតសាច់ដុំស្លាបប្រចៀវខាងឆ្វេង " កុម៉ារី ធូ សៀងមុី គិតចាប់ពីថ្ងៃនេះ តទៅ បើពោន សារឿន គ្មានប្រាក់សងគ្រប់ចំនួនទេត្រូវរឹបអូសទ្រព្យសម្បត្តិដែលមានលក់ ឡាយឡុងដើម្បីយកប្រាក់សងទៅដើមបណ្តឹង បើលក់ទ្រព្យសម្បត្តិសងមិនគ្រប់ចំនួនទៀតត្រូវដាក់គុក បង្ខំលើរូបរាងកាយ ។

៣- បង្គាប់អោយចុងចម្លើយ ពោន សារឿន បង់ប្រាក់ប្រដាប់ក្តីចំនួន៧០០០រៀលសងទៅ ដើមចោទវិញក្នុងនោះ ពន្ធប្តឹង និង ពន្ធចុះបញ្ជីក្តី ១៨០០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិប ប្រាក់២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ២០០០រៀល ចំណាយក្នុងការស៊ើបសួរ៣០០០រៀល ដែលប្រាក់នេះបានកាត់យកពីដើមបណ្តឹងបានបង់រួចហើយ កាលបើហួសឧទ្ធរណ៍ និង អោយដើមចោទ ផន វ៉ាន់ធូ បង់ពន្ធសមាមាត្រ១ភាគរយជាមុនសិនស្មើ៥៧.០០០រៀល "ប្រាំមុឺនប្រាំពីរពាន់រៀល" ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ៨០ភាគរយ ស្មើ៤៥.៦០០រៀល "បួនមុឺនប្រាំពាន់ប្រាំមួយរយរៀល" និងបង់ចូលរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០ភាគរយស្មើ ១១.៤០០រៀល រួចហើយអោយចុងចម្លើយ ពោន សារឿន បង់សងវិញជាក្រោយ ។

៤- សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងចុងចម្លើយ បើភាគីណាមិនសុខចិត្ត និង សេចក្តីសំរេចនេះទេ បើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ ពោន សារឿន មិនសុខចិត្តនិងសាលក្រមលេខ ១៩ចុះថ្ងៃទី១០មិនា១៩៩៩ ត្រង់ចំនុច សាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៥០៨ ចុះថ្ងៃទី ១៤តុលា១៩៩៩របស់សាលាឧទ្ធរណ៍មាន ខ្លឹមសារដូចតទៅ :-

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៣.០៤.១៩៩៩ របស់ឈ្មោះ ពោន សារឿន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់តែបដិសេធចោលដោយទាល់ខុស និង គតិច្បាប់ ។

---

២_ តំកល់សាលក្រមរដ្ឋប្បវេណីលេខ ១៩ ចុះថ្ងៃទី១០មិនា១៩៩៩ របស់តុលាការខេត្តព្រៃវែង ទុកជាបានការដដែល ។

៣_ សំរេចកាត់យកប្រាក់ប្រដាប់ក្តីចំនួន១៣.០០០រៀលដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ៥០០០រៀល និង ចំណាយលើអាជ្ញាធរតុលាការ៥០០០រៀល ។

៤_ សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមចោទកំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤៦៨ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៩ របស់ ឈ្មោះ ជុំ សោភា ជាមេធាវីការពារអោយឈ្មោះ ពោន សារឿន មិនសុខចិត្តនិងសាលដីការដ្ឋប្បវេណី លេខ ៥០៨ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៩ របស់ សាលាឧទ្ធរណ៍ ត្រង់ចំនុច សេចក្តី សំរេច នៃសាលដីកាទាំងមូល ។

បានឃើញសារណាការពាររបស់ឈ្មោះ ពោន សារឿន ចុះថ្ងៃទី ០៧មេសា ២០០០ ។

បានឃើញសារណាតប ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០០ ផ្ញូនមកតុលាការកំពូល របស់ ឈ្មោះ ផន វ៉ាន់ធួ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :

រឿងនេះសាលាឧទ្ធរណ៍បានសំរេចត្រឹមត្រូវតាមគតិច្បាប់ហើយ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាសំរេចតាមច្បាប់ចុះ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ពោន សារឿន នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា : ខ្ញុំយល់ថាកុមារីនេះសព្វថ្ងៃមានសុខភាពល្អធម្មតាទេ ម្តាយកុមារីនេះទេជាអ្នកយកកូនមកអោយខ្ញុំចាក់ថ្នាំដល់ផ្ទះ ហើយសូមអង្វរខ្ញុំអោយជួយព្យាបាលឯប្រាក់ថ្លៃព្យាបាលខ្ញុំមិនបានកំណត់ទេអាស្រ័យលើគេអោយ និង ថ្ងៃថ្នាំខ្ញុំបើកព្យាបាលមិនមានច្បាប់អនុញ្ញាតិទេកន្លងមកខ្ញុំព្យាបាលតាមជំនាញ និង បទពិសោធដែលបានរៀនខ្ញុំបានចាក់ថ្នាំព្យាបាលស្អួតនេះអោយកុមារី៤ម្ជុលដើមទ្រូង២ម្ជុល និង ក្រោយខ្នងពីរម្ជុលថ្លៃចាក់ថ្នាំនោះខ្ញុំបានតែ ២៦០០០រៀលទេដោយខ្ញុំយល់ថាកុមារីនេះមានជំងឺរាំរៃទើបខ្ញុំចាក់ថ្នាំនេះអោយ ក្រោយចាក់មានស្លាកស្នាមបន្តិចបន្តួចប៉ុណ្ណោះ សព្វថ្ងៃនេះក្មេងមានសភាពធម្មតាហើយ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ផន វ៉ាន់ធួ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា : ពេលកូនខ្ញុំក្តៅខ្លួន ចុងចម្លើយអោយខ្ញុំយកកូនទៅចាក់ថ្នាំនៅផ្ទះគាត់ក្រោយពីពិនិត្យហើយគាត់បានយកថ្នាំដែលចាក់សល់ពីគេយក

---

មកចាក់អោយកូនខ្ញុំដំបូងប្រុងចាក់ចំពង់ករទេ តែដោយកូនខ្ញុំស្រែកយំគាត់មកចាក់ដើមទ្រូង និងខ្នងវិញ ក្រោយចាក់ថ្នាំហើយកូនខ្ញុំរឹតតែក្តៅឡើង ក្រោយមកស្រាប់តែកូនខ្ញុំផតដើមទ្រូងតែម្តងពេលខ្ញុំសួរចុងចម្លើយនានាថា មិនអីទេ ពេលខ្ញុំនិយាយសំរួលជាមួយគាត់អោយព្យាបាលស្រួលវិញ គាត់បដិសេធរហូតដេញខ្ញុំអោយប្តឹង ដោយសារគ្រប់វេជ្ជបណ្ឌិតបញ្ជាក់ថា កូនខ្ញុំខូចសុខភាពហើយសព្វថ្ងៃកូនខ្ញុំនៅតែក្តៅរហូតសព្វថ្ងៃ ។

មេធាវីលោក សេង សុរីណា នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា: ក្រោយពីបានលើកឡើងរបស់ភាគីដើមចោទរួចមកខ្ញុំសូមបញ្ជាក់ឡើងវិញបន្តិចព្រោះ កូនក្តីខ្ញុំមិនសូវបានសំដីគាត់បានធ្វើពេទ្យយូរឆ្នាំមកហើយតាំងពីឆ្នាំ១៩៧៩ រហូតដល់សព្វថ្ងៃ សឹងតែដុកទ័រ មានបទពិសោធ មិនស្មើផង សូមបញ្ជាក់ថាគាត់ព្យាបាលតាមសីលធម៌ពេទ្យ ហើយមិនបានបើកគ្លីនិចយកកំរៃទេ ម្តាយកុមារីបានសុំអោយលោក ពោន សារឿន ជួយព្យាបាល ។ ខ្ញុំមិនមានបទពិសោធ ខាងពេទ្យទេ តែខ្ញុំយល់ថា គ្រប់ថ្នាំទាំងអស់តែងតែមានប្រតិកម្មចំពោះអ្នកប្រើ ឯលិខិតជាសំអាងរបស់ដើមចោទនោះ ពុំមានសុពលភាពខាងផ្លូវច្បាប់ទេ ពីព្រោះពុំមានការស្នើរសុំពី បង្គាប់បញ្ជាពីតុលាការឡើយ ព្រោះលិខិតនេះធ្វើជាលក្ខណៈឯកជន ហើយបង្ខំអោយកូនក្តីខ្ញុំសងឯទីកយ៏ប្រែយកមកសំអាងទៀតសោធថ្លៃព្យាបាលនោះថាអស់ជាងមួយពាន់ដុល្លារអាមេរិក ដូចជាពុំត្រឹមត្រូវទេ គួរណាស់ពិនិត្យ និង ពិចារណាឡើងវិញ ។ ខ្ញុំសូមអោយបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ជំរះឡើងវិញ ។

ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគីនិងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីចុងចម្លើយ

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា: បណ្តឹងសាទុក្ខលេខ៤៦៨ ចុះថ្ងៃទី១៨ខែ១០ឆ្នាំ ១៩៩៩ របស់លោកមេធាវី ជុំ សោភាស្ថិតក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់ សាលាជំរះក្តី ។

- យល់ឃើញថា: ការដែលសាលាឧទ្ធរណ៍លើកឡើងតាមលិខិតវេជ្ជបញ្ជាចុះថ្ងៃទី២៣.១១.៩៨ របស់មន្ទីរពេទ្យកុមារជាតិថាជម្ងឺរបស់កូនដើមចោទមិនអាចព្យាបាលបានដូចដើមវិញព្រោះជាតិថ្នាំដែលចាក់ធ្វើអោយស្វិតជាលិកាខ្លាញ់ និង សាច់ដុំត្រង់ស្នាមប្រចៀវនោះជាការពុំទាន់ត្រឹមត្រូវទេពីព្រោះថាលិខិតបញ្ជាក់ខាងលើនេះធ្វើឡើងដោយដើមចោទផ្ទាល់មិនមែនជាលិខិតដែលស្នើសុំដោយតុលាការក្នុងការធ្វើកោសល្យវិច័យតាមលក្ខណៈផ្លូវការឡើយ ។

- យល់ឃើញថា : សំអាងខាងលើរបស់ដើមចោទពុំទាន់មានលិខិតកោសល្យវិច័យលើជម្ងឺរបស់កុមារីជាកូនដើមចោទថាតើអាចជាដូចដើមវិញឬក៏ពិការអចិន្ត្រៃយ៍រហូតអស់មួយជីវិតនៅឡើយ

- - - - - - - - - - - - - - - - - - - - - - - - - - - - - - - -

ដូច្នេះគប្បីធ្វើការស៊ើបអង្កេតបន្ថែមលើស្ថានភាពសុខភាពរបស់កុមាររងគ្រោះនិងការព្យាបាលបន្ទាប់ពីចាក់ថ្នាំនោះ ។

- យល់ឃើញថា ៖ សាលដីការដ្ឋប្បវេណីលេខ៥០៨ ចុះថ្ងៃទី១៤.១០.៩៩របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ៤៦៨ចុះថ្ងៃទី១៨.១០.៩៩របស់លោកជុំ សោភា ទុកជាត្រឹមត្រូវតាមទំរង់និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៥០៨ ចុះថ្ងៃទី១៤.១០.៩៩របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១០៧ចុះថ្ងៃទី០២.០៣.២០០០របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីដែលលោកពោន សារឿនបានបង់ទុកនៅតុលាការកំពូលចំនួន១៩.០០០រ

គឺ - ពន្ធចុះបញ្ជីក្តីនិងពន្ធហ៊ីងចំនួន៤០០០រៀលប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀលសំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

- ចំណាយក្នុងកិច្ចប្រគល់ដីការកោះចំនួន១៥.០០០រៀលសរុប ១៩.០០០រៀលហើយត្រូវអោយដើមចោទសងប្រាក់ចំនួន១៩.០០០នេះទៅចុងចម្លើយវិញ ។

៥- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៣ ខែ សីហា ឆ្នាំ ២០០១ ។